មើលវីដេអូ ភាគទី ៣២

# វិនិច្ឆ័យបិសុណាវាទ (ពាក្យញុះញង់) ដោយអាការ ៥ ៖

១ - ដោយមូល មានមូល៣ គឺ លោភមូល ទោសមូល និងមោហមូល

២ - ដោយកម្ម ជាវចីកម្ម

៣ - ដោយទ្វារ សម្រេចតាមទ្វារ ២ គឺកាយទ្វារ និងវចីទ្វារ

ស្កេនដើម្បីមើលមេរៀន
San Sochea Official

## ៤ - ដោយទោស មានទោសខុសគ្នាយ៉ាងនេះ គឺ ៖

- ញុះញង់ឲ្យអ្នកដទៃខូចប្រយោជន៍ច្រើន មានទោសច្រើន
- ញុះញង់ឲ្យអ្នកដទៃខូចប្រយោជន៍តិច មានទោសតិច
- អ្នកដទៃបែកគ្នាដោយការញុះញង់នោះ មានទោសច្រើន
- បើគេមិនបែកគ្នាដោយការញុះញង់នោះ មានទោសតិច
- កិលេសនិងការព្យាយាមខ្លាំង មានទោសច្រើន
- កិលេសនិងការព្យាយាមខ្សោយ មានទោសតិច

## ៥ - ដោយអង្គ បិសុណាវាទ មានអង្គ ៤ គឺ ៖

- ភិន្ទិតព្វោ បរោ — មានអ្នកដទៃដែលខ្លួនគប្បីញុះញង់បំបែក
- ភេទបុរេក្ខារតា — គិតនឹងញុះញង់បំបែកអ្នកដទៃនោះ
- តជ្ជោ វាយាមោ — ព្យាយាមបំបែកអ្នកដទៃនោះ
- តស្ស តទត្ថវិជាននំ — ញុំាំងអ្នកដទៃឲ្យដឹងច្បាស់នូវរឿងដែលខ្លួនញុះញង់នោះ។

** កាលណាគ្រប់អង្គទាំង៤ ឈ្មោះថាដាច់កម្មបថ បើមិនគ្រប់អង្គមិនឈ្មោះថាដាច់កម្មបថទេ ប៉ុន្តែអាចជាទុច្ចរិតកម្ម។*

## វិនិច្ឆ័យផរុសវាទ (ពាក្យសំដីអាក្រក់) ដោយអាការ៥ ៖

១ - ដោយមូល មានមូល២ គឺទោសមូល និងមោហមូល

២ - ដោយកម្ម ជាវចីកម្ម

៣ - ដោយទ្វារ សម្រេចតាមទ្វារ ២ គឺកាយទ្វារ និងវចីទ្វារ

## ៤ - ដោយទោស មានទោសខុសគ្នាយ៉ាងនេះ គឺ ៖

| | |
|---|---|
| - ជេរមនុស្សល្អ | មានទោសច្រើន |
| - ជេរមនុស្សអាក្រក់ | មានទោសតិច |
| - កិលេសនិងការព្យាយាមខ្លាំង | មានទោសច្រើន |
| - កិលេសនិងការព្យាយាមខ្សោយ | មានទោសតិច |

## ៥ - ដោយអង្គ ផរុសវាទមានអង្គ៣ គឺ ៖

- អក្កោសិតព្វោ បរោ មានអ្នកដទៃដែលខ្លួនគប្បីជេរ
- កុបិតចិត្តំ មានចិត្តខឹងក្រោធ
- អក្កោសនា បានជេរប្រទេច

* *កាលណាគ្រប់អង្គទាំង ៣ ឈ្មោះថាដាច់កម្មបថ បើមិនគ្រប់អង្គ មិនឈ្មោះថាដាច់កម្មបថទេ ប៉ុន្តែអាចជាទុច្ចរិតកម្ម។*

## វិនិច្ឆ័យសម្ផប្បលាបវាទ (ពាក្យសំដីឥតប្រយោជន៍) ដោយអាការ៥ ៖

១ - ដោយមូល មានមូល៣ គឺលោភមូល ទោសមូល និង មោហមូល

២ - ដោយកម្ម ជាវចីកម្ម

៣ - ដោយទ្វារ សម្រេចតាមទ្វារ ២ គឺកាយទ្វារ និងវចីទ្វារ

## ៤ - ដោយទោស មានទោសខុសគ្នាយ៉ាងនេះ គឺ ៖

- និយាយច្រើន មានទោសច្រើន
- និយាយតិច មានទោសតិច
- អ្នកដទៃកាន់យកនូវរឿងឥតប្រយោជន៍នោះ មានទោសច្រើន
- អ្នកដទៃមិនកាន់យកនូវរឿងឥតប្រយោជន៍នោះ មានទោសតិច

## ៥ - សម្ផប្បលាបវាទ មានអង្គ២ គឺ ៖

- និរត្ថកថា បុរេក្ខារតា ចិត្តចង់និយាយរឿងឥតប្រយោជន៍
- តថារូបីកថា កថនំ បាននិយាយនូវរឿងឥតប្រយោជន៍ មានភាពដូច្នោះ។

** កាលណាគ្រប់អង្គទាំង២ ឈ្មោះថាដាច់កម្មបថ បើមិនគ្រប់អង្គ មិនឈ្មោះថាដាច់កម្មបថទេ ប៉ុន្តែអាចជាទុច្ចរិតកម្ម។*

## * ចំណាំ

ការនិយាយដោយបំណងឲ្យអ្នកដទៃដឹងនូវរឿងឥតប្រយោជន៍ប៉ុណ្ណោះ ទើបចាត់ជាអកុសលកម្មបថ បើមិនមានបំណងឲ្យគេដឹងរឿងឥតប្រយោជន៍ទេ មិនចាត់ជាអកុសលកម្មបថឡើយ ប៉ុន្តែជាទ្វារនៃអកុសលចិត្ត។